**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៨១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្តល់ប្រាក់បំណាច់មុខងារ ជូនកងយោធពលខេមរភូមិន្ទ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ១៧.អនក្រ.បក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការកែសំរួលប្រព័ន្ធបៀវត្សរបស់កងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ៨៥.អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០២ ស្តីពីការបង្កើនប្រាក់ម្ហូបអាហារជូនកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ១៨៥.អនក្រ.បក ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការកែសំរួលប្រាក់បៀវត្សមូលដ្ឋានរបស់កងយោធពលខេមរភូមិន្ទ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១.**-អនុក្រឹត្យនេះមានគោលដៅផ្តល់ប្រាក់បំណាច់មុខងារជូនដល់កងយោធពលខេមរភូមិន្ទ ។

**មាត្រា២.**-ប្រាក់បំណាច់មុខងារ គឺជាប្រាក់របបប្រចាំខែដែលបានចែកចេញជាជប់ប្រាំមួយមុខដំណែង និងត្រូវផ្តល់ជូនទៅតាមអតីតភាពចាប់ពីពេលបានចូលបំរើការងារក្នុងកងយោធពលខេមរភូមិន្ទ ដូចមានកំណត់ក្នុងតារាងខាងក្រោម ៖

| ល.រ | មុខតំណែងជាមូលដ្ឋាន | ប្រាក់បំណាច់មុខងារ ផ្តល់តាមអតីតភាព (ឯកតារៀល) | | | | |
|---|---|---|---|---|---|---|
| | | ក្រោម៣ឆ្នាំ | ០៣ដល់០៦ឆ្នាំ | ០៧ដល់១០ឆ្នាំ | ១១ដល់១៦ឆ្នាំ | ១៧ឆ្នាំឡើង |
| ១ | អគ្គមេបញ្ជាការ | ១.៥៥០.០០០ | ១.៦០០.០០០ | ១.៦៥០.០០០ | ១.៧០០.០០០ | ១.៧៥០.០០០ |
| ២ | អគ្គមេបញ្ជាការរង | ៧៥០.០០០ | ៧៩៥.០០០ | ៨៤៣.០០០ | ៨៩៤.០០០ | ៩២៩.០០០ |
| ៣ | មេបញ្ជាការ យោធភូមិភាគ | ៦២០.០០០ | ៦៥៨.០០០ | ៦៩៨.០០០ | ៧៤១.០០០ | ៧៨៦.០០០ |
| ៤ | មេបញ្ជាការ កងពលធំ | ៥៣០.០០០ | ៥៧០.០០០ | ៦១០.០០០ | ៦៥០.០០០ | ៦៩០.០០០ |
| ៥ | មេបញ្ជាការ កងពលតូច | ៤៣០.០០០ | ៤៥០.០០០ | ៤៧០.០០០ | ៤៩០.០០០ | ៥១០.០០០ |
| ៦ | មេបញ្ជាការ កងវរសេនាធំ | ៣៨០.០០០ | ៤០០.០០០ | ៤២០.០០០ | ៤៤០.០០០ | ៤៦០.០០០ |
| ៧ | មេបញ្ជាការ កងវរសេនាតូច | ៣១០.០០០ | ៣៣០.០០០ | ៣៥០.០០០ | ៣៧០.០០០ | ៣៩០.០០០ |
| ៨ | បញ្ជាការរងកងវរសេនាតូច | ២៦០.០០០ | ២៨០.០០០ | ៣០០.០០០ | ៣២០.០០០ | ៣៤០.០០០ |
| ៩ | មេបញ្ជាការ កងអនុសេនាធំ | ២០០.០០០ | ២២០.០០០ | ២៤០.០០០ | ២៦០.០០០ | ២៨០.០០០ |
| ១០ | បញ្ជាការរងកងអនុសេនាធំ | ១៥០.០០០ | ១៦៥.០០០ | ១៨០.០០០ | ១៩៥.០០០ | ២១០.០០០ |
| ១១ | មេបញ្ជាការ កងអនុសេនាតូច | ១២០.០០០ | ១៣៥.០០០ | ១៥០.០០០ | ១៦៥.០០០ | ១៨០.០០០ |
| ១២ | មេបញ្ជាការរងកងអនុសេនាតូច | ៩០.០០០ | ១០០.០០០ | ១១០.០០០ | ១២០.០០០ | ១៣០.០០០ |
| ១៣ | នាយក្រុម | ៦០.០០០ | ៦៥.០០០ | ៧០.០០០ | ៧៥.០០០ | ៨០.០០០ |
| ១៤ | នាយក្រុមរង | ៤៦.០០០ | ៤៧.០០០ | ៤៨.០០០ | ៤៩.០០០ | ៥០.០០០ |
| ១៥ | នាយពួក | ៤៤.០០០ | ៤៥.០០០ | ៤៦.០០០ | ៤៧.០០០ | ៤៨.០០០ |
| ១៦ | យុទ្ធជន | ៤១.០០០ | ៤២.០០០ | ៤៣.០០០ | ៤៤.០០០ | ៤៥.០០០ |

**មាត្រា៣.**-មុខតំណែងដទៃទៀតដែលសមមូលនឹងមុខតំណែងជាមូលដ្ឋានខាងលើ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ ។

**មាត្រា៤.**-យោធិនដែលកំពុងស្ថិតក្នុងមុខតំណែងណាមួយ ត្រូវទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងនោះ។ ករណីយោធិនដែលកាន់មុខតំណែងច្រើន ត្រូវអនុញ្ញាតអោយជ្រើសរើសយកប្រាក់បំណាច់មុខងារតែមួយគត់ ។

**មាត្រា៥.**-ការកែប្រែចំនួនមុខតំណែងជាមូលដ្ឋាន ឬប្រាក់បំណាច់មុខងារខាងលើ ត្រូវចែងដោយអនុក្រឹត្យ ។

**មាត្រា៦.**-យោធិនដែលមានសិទ្ធិទទួលប្រាក់បំណាច់មុខងារ ត្រូវស្ថិតក្នុងលក្ខខណ្ឌដូចខាងក្រោម ៖

១-កំពុងបំពេញការងារក្នុងកងយោធពលខេមរភូមិន្ទ .

២-កំពុងផ្លាស់ប្តូរកន្លែងធ្វើការ និងកំពុងធ្វើដំណើរទៅកាន់មុខតំណែង នៅក្នុង ឬក្រៅប្រទេស

៣-កំពុងបំពេញការសិក្សាក្នុងនិងក្រៅប្រទេសតាមតំរូវការរបស់កងទ័ព

៤-យោធិនពលី ពិការ សោធននិវត្តន៍ ដែលមិនទាន់ផ្ទេរទៅអោយក្រសួងស្ថាប័នពាក់ព័ន្ធគ្រប់គ្រងបន្ត

៥-យោធិនដែលបានអនុញ្ញាតច្បាប់ក្នុងធុរៈផ្ទាល់ រយៈពេលសំរាកព្យាបាលជម្ងឺ និងជាប់ខ្លួនក្នុងបេសកកម្ម

**មាត្រា៧.**-ការបញ្ឈប់ផ្តល់ប្រាក់បំណាច់មុខងារ ត្រូវធ្វើទៅតាមថ្ងៃខែបានកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ក្នុងករណីដូចខាងក្រោម ៖

១-យោធិនដែលសុំលាឈប់ពីការងារ ដោយមានការអនុញ្ញាត

២-យោធិនដែលមានសេចក្តីប្រកាសបណ្តេញចេញពីកងយោធពលខេមរភូមិន្ទ

៣-យោធិនដែលអវត្តមានគ្មានការអនុញ្ញាត ឬហួសកំណត់ដោយប្រធានស័ក្តិមិនសមស្រប

៤-យោធិនពលី ពិការ និវត្តន៍ជន ដែលបានផ្ទេរទៅអោយក្រសួងស្ថាប័នពាក់ព័ន្ធគ្រប់គ្រងបន្តរួចហើយ

៥-យោធិនដែលមានសាលក្រមរបស់តុលាការបញ្ជាក់ថាជាទណ្ឌិត

**មាត្រា៨.**-ប្រាក់របបផ្សេងៗទៀត ក្រៅពីប្រាក់បំណាច់មុខងារ ត្រូវបន្តអនុវត្តជាធរមាន។

**មាត្រា៩.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០០៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជូន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

សូមចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**ទៀ បាញ់**

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ